ឧបសោសង្ហា

១៨ មករា ២០១៧

---

# កម្លាំងចលករ



---

## ការសាកល្បងពិចារណា



សេរីការ

**កម្លាំងចលករ**

# មាតិការឿង


អារម្ភកថា........................................................2

តើ នរណា ជា ចលករ នៃ កម្លាំងជាតិ ?......5


# អារម្ភកថា

សេចក្តីសង្ឃឹម វា ជា ខ្លឹមសារ នៃ មនុស្សលោក ទោះបី មនុស្សនោះ ស្ថិត នៅក្នុង ស្ថានភាព បែបណា ក៏ដោយ។ រហូត នៅ លើរាន ពិឃាត ទោសប្រហារជីវិត ទណ្ឌិត ក៏ នៅ មាន សេចក្តីសង្ឃឹម ថា ខ្លួន នឹងជួប បាដិហារិយ៍ ណា មួយ ដែល អាច អោយ ខ្លួន រួច ទោស ផង នោះ ដែរ។ មួយ វិនាទី នៃ ដង្ហើម របស់ មនុស្សលោក វា ជា ពលវេគ នៃ កម្លាំង នៃ សេចក្តីសង្ឃឹម សំរាប់ ជីវិត។ នៅក្នុង សេចក្តី សង្ឃឹម នេះឯង ដែល យើង ជូន ពរ សព្វសាធុការ ដល់ ប្រជាពលរដ្ឋខ្មែរ សំរាប់ ជីវិត នៅក្នុង ឆ្នាំ សកល ២០១៧។

ប្រជាជាតិខ្មែរ ត្រូវការ ចាំបាច់ នូវ សេចក្តីសង្ឃឹមរួម របស់ ខ្មែរ ម្នាក់ៗ ដើម្បី រំដោះជាតិ ពី អាណានិគមយួន និង របប លួច[1] (kleptocratie) ដែល ជា កត្តា នៃ វិនាដកម្ម ជាតិ សព្វថ្ងៃ។ គួរ ខ្មែរ ម្នាក់ៗ យល់ដឹង ថា សេចក្តីសង្ឃឹម លើ ការបោះឆ្នោត នៅក្នុង បរិបទ នយោបាយខ្មែរ សព្វ

[1] របប លួច ជា របប ពុករលួយ ដឹកនាំដោយ ពួក លួចជាតិ។

ថ្ងៃ វា ជា សេចក្តីសង្ឃឹម ក្នុង ការអស់សង្ឃឹម តែប៉ុណ្ណោះ ព្រោះ វា មិនអាច នឹង មាន ការបោះឆ្នោត ដោយ សេរី និង យុត្តិធម៌ នោះឡើយ បើគ្មាន អង្គការជាតិ និង អន្តរជាតិ ឯករាជ្យ សំរាប់ ត្រួតពិនិត្យ នៃ ការបោះឆ្នោត។ គ.ជ.ប. បច្ចុប្បន្ន ជា ឧបករណ៏ របស់ គណបក្ស កាន់អំណាច និង គណបក្សប្រឆាំង មាន អាសនៈ នៅក្នុង រដ្ឋសភា កំពុង ស្រុះស្រួល ចែក ប្រយោជន៏ គ្នា ដូច នៅក្នុង អាណត្តិ ទី៥ នេះ។ គ្រប់ គណបក្សនយោបាយ ដែល កំពុង រៀបចំ ខ្លួន ចូលរួម បោះឆ្នោត និង សេរីភាព របស់ លោក កឹម សុខា គឺ គ្រាន់តែ ជា គ្រឿងលំអ របស់ អាណានិគម យួន សំរាប់ បិទ មាត់ សហគម អន្តរជាតិ នៅក្នុង នាម នៃ អធិបតេយ្យភាព នៃ ប្រជាជាតិខ្មែរ តែ ប៉ុណ្ណោះ។

ចុះ បើ គ្មាន សេចក្តីសង្រ្គឹម លើ ការបោះឆ្នោត ដែល ជា សន្តិវិធី សំរាប់ ជ្រើសរើស អ្នកដឹកនាំ តើ ប្រជាពលរដ្ឋ អាចនឹងមាន វិធី អ្វី ផ្សេងទៀត ដើម្បី បំពេញ សិទ្ធិ និង ករណីយកិច្ច របស់ ខ្លួន ជា ពលរដ្ឋ ?

ការបោះឆ្នោត វា គ្រាន់តែ ជា វិធី ទីក្រោម (en aval) នៃ លទ្ធិប្រជាធិបតេយ្យ ដែល គេ យក វា មក អនុវត្ត នៅ ពេល ណា ដែល លទ្ធិ នោះ វា មាន គុណភាព ពេញលេញ របស់ វា សំរាប់ ធ្វើ ការបោះឆ្នោត ពុំ នោះ សោត ការបោះឆ្នោត នោះ វា គ្រាន់តែ ជា ការបញ្ឆោត សំរាប់ បំរើ ផល

ប្រយោជន៍ របស់ ពួក អ្នក យក វា មក អនុវត្ត តែ ប៉ុណ្ណោះ។ គុណភាព ពេញលេញ របស់ លទ្ធិប្រជាធិបតេយ្យ គឺ ជា អាទិ ប្រជាជាតិ ត្រូវ មាន ឯករាជ្យ ពេញលេញ ហើយ ពលរដ្ឋ ម្នាក់ៗ មាន បុណ្ណភាព (plénitude) នៃ សិទ្ធិ អាច មាន ជម្រើស តាម សេរី និង អធិបតេយ្យ នូវ របប ឬ អ្នក ដឹកនាំ ជាតិ ដោយ គ្មាន ការបារម្ភ ពី និរន្តរាយ ដល់ ជីវិត ផ្ទាល់ របស់ ខ្លួន។ គុណភាព នៃ ជម្រើស គឺ ស្ថិត នៅលើ គុណសម្បត្តិ នៃ ប្រជាពលរដ្ឋ គឺ ថា បើ ប្រជាពលរដ្ឋ ស្គាល់ ច្បាស់លាស់ អំពី ប្រយោជន៍ជាតិ និង ប្រយោជន៍រួម គឺ ពិត ជា ជម្រើស មាន ប្រយោជន៍ ដល់ ប្រជាជាតិ។ តែ បើ ជម្រើស សំរាប់ តែ ប្រយោជន៍ អាត្មា ឬ អត្តទត្តភាព គឺ វា គ្រាន់តែ ជា ចំនួន ជម្រើស ខ្លៅ ឬ ខ្វាក់ ដែល នាំ ប្រជា ជាតិ ដើរ ដោយ ចៃដន្យ ទៅ រក មហន្តរាយ។ ដូច្នេះ ករណីយកិច្ច របស់ ពលរដ្ឋ ម្នាក់ៗ គឺ ស្គាល់ សម្មានភាព របស់ គណបក្ស ឬ អ្នកដឹកនាំ ដែល ខ្លួន ជ្រើសរើស។ បើ ពិត ជា ស្គាល់ គុណសម្បត្តិ និង គុណវិបត្តិ របស់ អ្នក ដឹកនាំ ឬ បក្ស ដែល ខ្លួន ជ្រើសរើស ពលរដ្ឋ នោះ ត្រូវ មាន សេចក្តី ក្លាហាន ពន្យល់ និង ផ្សាយ នូវ ការយល់ដឹង នោះ ជា គំនិត សមញ្ញ ដល់ អ្នកដទៃ ស្រួលយល់ ដើម្បី អោ យ គ្រប់គ្នា បាន យល់ សំរាប់ ជម្រើស មាន ប្រយោជន៍ ដល់ ប្រជាជាតិ។ បើ ជ្រើសរើស ដោយ មិន ស្គាល់ នូវ គុណ

សម្បត្តិ និង គុណវិបត្តិ អ្នកដឹកនាំ គឺ ជា បញ្ញាណ[2] នៃ សេចក្តី ល្ងង់ខ្លៅ តែ បើ ស្គាល់ ហើយ មិន ខំ ពន្យល់ ឬ លាក់បាំង ដល់ អ្នកដទៃ គឺ ជា បញ្ញាណ នៃ ទុព្វលភាព និង ភាពកំសាក របស់ ខ្លួន។

អ្នក ដែល យល់ដឹង អំពី គុណសម្បត្តិ និង គុណវិបត្តិ នៃ គណបក្ស ឬ អ្នកដឹកនាំ និង បរិបទ នយោបាយ នេះ ហើយ ជា មេខ្នាត នៃ កម្លាំងជាតិ រាប់ ពី មួយ ទៅ។ តែ បើ ចំនួន អ្នកយល់ដឹង នោះ កាន់ តែ កើនឡើងៗ វា នឹង ក្លាយ ជា ចលករ នៃ កម្លាំងជាតិ ឬ ជា ពន្លឺ នៃ ការចេះដឹងជាតិ សំរាប់ លុបបំបាត់ គ្រប់ អំពើ សៅហ្មង ឬ ថោកទាប ដល់ ប្រជាជាតិ។

## តើ នរណា ជា ចលករ នៃ កម្លាំងជាតិ ?

### គណបក្ស នយោបាយ ?

ជា គោលការណ៍ គឺ គណបក្ស នយោបាយ ខ្លួនឯង ជា ពន្លឺ នៃ ការចេះដឹងជាតិ ព្រោះ ខ្លួន មាន ឆន្ទះ និង សក្តានុពល សំរាប់ ដឹកនាំជាតិ។ តួនាទី របស់ គណបក្ស នយោបាយ មិនត្រឹមតែ បង្ហាញ ជាក់លាក់ នូវ សមត្ថភាព និង សមត្ថកិច្ច នៃ អ្នកដឹកនាំ ដល់ ម្ចាស់ឆ្នោត ថា

[2] បញ្ញាណ; ព័ស្តុតាង; preuve។

អាចនឹង ដឹកនាំជាតិ បាន ប៉ុណ្ណោះឡើយ គឺ ត្រូវ មាន ករណីយកិច្ច ធ្វើ ការអប់រំ នយោបាយ ដល់ ប្រជាពលរដ្ឋ។ និយមន័យ នៃ ពាក្យ ស្រឡាញ់ជាតិ, សេរីភាព, សិទ្ធិ និង ករណីយកិច្ច របស់ ពលរដ្ឋ ត្រូវ យក វា មក បកស្រាយ ជាជម្រៅ មិន អោយ វា ស្ថិតនៅ តែ ជា សភាវគតិ និង មនោសញ្ចេតនា ព្រោះ ស្ថានភាព បែប នេះ មិន អាច ទប់ទល់ និង ទទួលរង នឹង សិទ្ធិអំណាច បានយូរ នោះឡើយ។ តែ បើ មាន ការអប់រំ នយោបាយ មិនច្បាស់លាស់ គឺ អិនអាច បង្កើត នូវ សហប្រតិបត្តិការ រវាង ការចេះដឹង នយោបាយ នឹង បញ្ញា នៃ មនុស្ស នៅក្នុង រូបសន្ត (calme) និង និយតភាព នៃ នយោបាយជាតិ។ កង្វះ នេះ នឹងអាច មាន កើត មហន្តរាយជាតិ នៅពេល ណា មួយ ជា ពុំខាន។

នៅ ស្រុកខ្មែរ គណបក្ស កាន់អំណាច មិនបាន បំពេញ ករណីណកិច្ច នោះឡើយ ព្រោះ តែ មាន អាទិភាព ដាច់ខាត គឺ រក្សា អំណាច ដូច្នេះ ខ្លួន ទុក ប្រយោជន៍ នៃ គណបក្ស ជា ប្រយោជន៍ ពិសាល ជាង ប្រយោជន៍ជាតិ។ លើស ពី នេះ ទៅទៀត គណបក្ស កាន់អំណាច ជា គណបក្ស រណប យួនកុម្មុយនិស្ត ស្ម័គ្រចិត្ត ទទួលយក អាណានិគម យួន ជា អំណាច ដឹកនាំ ជាតិខ្មែរ ព្រោះ ជា អំណាច

ការពារ បុព្វសិទ្ធិ របស់ ខ្លួន ប្តូរនឹង អ្វី គ្រប់បែបយ៉ាង ដែល យួន គេ ចង់បាន។

រីឯ គណបក្ស ប្រឆាំង គ្មាន គោលជំហរ ច្បាស់លាស់ ដូច្នេះ ខ្លួន ពុំអាច បំពេញ ករណីយកិច្ច ជា ចលករ នៃ កម្លាំង ជាតិ បាន នោះដែរ អាស្រ័យ ហេតុនេះ នាំ បង្ហាញ អោយ ឃើញ នូវ សកម្មភាព របស់ ខ្លួន ជា អ្នកប្រឆាំង សំរាប់ តែ លំអ របប អាណានិគមយួន តែ ប៉ុណ្ណោះ។ ដូចយ៉ាង គណបក្ស សង្គ្រោះជាតិ មាន សកម្មភាព ត្រឹមតែ សង្គ្រោះ អ្នកដឹកនាំបក្ស ស្ទើរ តែ មិនបាន ផង។ ដើម្បី រស់ បាន សុខ ពួក អ្នកដឹកនាំបក្ស សុខចិត្ត ធ្វើសិថិលភាព (ការសម្រុះសម្រួលគ្នា) គ្រប់ បែបយ៉ាង ជា មួយ គណបក្ស កាន់អំណាច ដែល ធ្វើ អោយ ច្របូកច្របល់ នូវ ទិស ពិត នៃ ប្រយោជន៏ជាតិ និង ស្មាញទ្រា (empêtré) ក្នុង ជម្លោះ ផ្ទៃក្នុង របស់ បក្ស។ នាំ គ្នា សម្ងំរស់ នៅក្នុង វប្បធម៏ សន្ទនា ដូច ជា អ្នក ជំពាក់ គុណ លោក ហ៊ុន សែន សងមិនដាច់ ដូចយ៉ាង នៅពេល ថ្មីៗនេះ នាំ គ្នា ដកងារ លោក សមរង្ស៊ី ដើម្បី បំពេញ ចិត្ត លោក ហ៊ុន សែន ប្តូរនឹង សេរីភាព មាន កំរិត និង អាម៉ាស់កេរ្តិ៍ របស់ លោក កឹម សុខា និង ប្រយោជន៏ ទុច្ចរិត រៀងៗខ្លួន។

ចំណែក គណបក្ស ផ្សេងៗទៀត ដែល កំពុង រៀបចំ ខ្លួន ចូលរួម បោះឆ្នោត សំរាប់ តែ អោយ យួនឈ្នះ គ្រាន់ តែ

ជា តូរ្យតន្ត្រី[3] សំរាប់ លេង បន្ទរ នៅក្នុង ពាទ្យភណ្ឌ[4] របស់ យួន តែ វា មាន សម្លេងល្អើយ ដែល នាំ អោយ គេ ស្តាប់ បាន ថា វា មិនមែន ជា សម្លេង នៃ លទ្ធិប្រជាធិបតេយ្យ ឬ សម្លេង នៃ ប្រយោជន៏ខ្មែរ។ ដូច្នេះ គណបក្ស ទាំងនោះ មិនអាច ដើរ តួនាទី ជា ចលករ នៃ កម្លាំងជាតិ បាន នោះឡើយ។

រួមសេចក្តីមក គ្រប់ គណបក្ស នយោបាយ រស់ នៅក្នុង អប្បបញ្ញា នាំ គ្នា វាយប្រហារ គ្នា នៅ ក្នុង ប្រព័ន្ធ នៃ យុទ្ធ សាស្ត្រយួន ដែល មាន គណបក្ស កាន់អំណាច ជា មេ ពាទ្យភណ្ឌ សំរាប់ អោយ ចង្វាក់ យាត្រា នាំ គ្នា ដើរ ចូល ទៅ ក្នុង សហព័ន្ធ ឥណ្ឌូចិន មាន យួនកុម្មុយនិស្ត ជា ចៅ ហ្វាយ។

## បញ្ញាវន្ត ?

នៅ ស្រុកខ្មែរ ចាប់ ពី ១៩៧៥ មក ពី របប នយោបាយ មួយ ទៅ របប នយោបាយ មួយទៀត វា គ្រាន់ តែ ជា ការ បន្ត នូវ វិបត្តិ នយោបាយ ដែល នាំ អោយ សង្គមខ្មែរ គ្មាន គំណល់ ជាថាមវន្ត នៃ គំនិតជាតិ ច្បាស់លាស់។ កង្វះ នេះ មិនអាច អោយ សង្គមខ្មែរ ធ្វើសមោធនា នូវ បញ្ញា

---

[3] តូរ្យតន្ត្រី; Instruments de musique។
[4] ពាទ្យភណ្ឌ ;Orchestre។

ជាតិ ឈ្វេងយល់ ដែល ជា ចលករ សំរាប់ ផ្លាស់គំនិតជាថ្មី នៅក្នុង សង្គម ថំហ ដើម្បី ប្រឈមមុខនឹង អនុភាព នៃ លោកូបនីយកម្ម។ នៅក្រោម របប បដិវត្តន៍ របស់ ខ្មែរក្រហម វា មាន និស្លាបកម្ម (ការបំផ្លាញ) ជាប្រពន្ធិក[5] នូវ មូលដ្ឋាន នៃ ធម្មជាតិ នៃ មនុស្សលោក គឺ គ្រួសារ, ប្រជាជាតិ និង វិជ្ជា ដោយ យក មូលដ្ឋាន បដិវត្តន៍ មក ជំនួស គឺ បក្ស, សង្គម កុម្មុយនិស្ត និង ការប្រតិបត្តិ។ ការបំផ្លាញ នេះ មាន គោលបំណង ប្តូរ ជនខ្មែរ ជា នរជន អោយ ទៅ ជា ជនកុម្មុយនិស្ត ជា អ្នកបំរើ ស្ម័គ្រចិត្ត របស់ បក្ស កុម្មុយនិស្ត។ ការប្តូរ នេះ បំផ្លាញ បញ្ញាជាតិ គ្រប់ វិស័យ។

នៅក្រោម របប យួន ត្រួតត្រា ផ្ទាល់ (១៩៧៩-១៩៨៩) វា មាន និស្លបកម្ម ជា ស្វ័យប្រវត្តិ នូវអត្តសញ្ញាណ ជាតិសាសន៍ខ្មែរ គឺ ខ្មែរម្ចាស់ស្រុកខ្មែរ, ប្រជាជាតិខ្មែរ និង តម្លៃ នៃ ការតស៊ូខ្មែរ ដោយ យក អត្តសញ្ញាណ ថ្មី គឺ ខ្មែរ ជា អ្នកស្រុក មួយ ក្នុង ចំណោម អ្នកស្រុក ដ៏ទៃទៀត មាន យួន ចិន ចាម ។ល។ ការបំផ្លាញ នេះ មាន គោលដៅ រំលាយ ប្រជាជាតិខ្មែរ គឺថា អោយ ប្រជាជនខ្មែរ ក្លាយ ជា ប្រជាពលរដ្ឋ ភាគតិច នៅលើ ទឹកដី ដែល ខ្លួន រស់នៅ។

[5] ការបំផ្លាញ ជា ប្រពន្ធិក ; une destruction systématique។

នៅក្រោម របប អាណានិគមយួន សព្វថ្ងៃ វា មាន ការ បំផ្លាញ ប្រព័ន្ធ ដឹកនាំជាតិ ឋបនកម្ម (installé) ដោយ កិច្ចព្រមព្រៀង សន្តិភាព ថ្ងៃទី ២៣ តុលា ឆ្នាំ ១៩៩១ គឺ លទ្ធិប្រជាធិបតេយ្យ ដោយ យក របប លួច ដើម្បី បង្កើត អសន្តិសុខ នៅក្នុង សង្គម ធ្វើ អោយ សង្គម ក្លាយ ជា សង្គម តិរច្ឆាន ដោយសារ តែ មាន អ្នកដឹកនាំ គ្រប់ លំដាប់តំណែង មាន ចារិត ជា អន្ធជន[6] ជា មហាត បំផ្លាញជាតិ។

នៅក្នុង បរិស្ថាន ដែល បានរៀបរាប់ ខាង លើ នេះ មិន អាច មាន ដុះ បញ្ញាវន្ត ជា ជន មាន ប្រាជ្ញា ជា អ្នក ប្រព្រឹត្តល្អ ជា អ្នកកាន់ សុចរិត ដោយ ពិស្តា ដោយ ខ្ជាប់ ខ្ជួន ហ្មត់ចត់ ជា និច្ច គឺថា ជា អ្នកប្រាជ្ញ ខាង ផ្លូវ សុចរិត និង យុត្តិធម៌ មាន ភារៈ ជា ឧត្តមជន ឯករាជ្យ សំរាប់ ជា យាន នៃ ការរីកចំរើន នៃ សង្គម និង ជា យោង នៃ បញ្ញា ជាតិ ដែល ជា កម្លាំងចលករ ត្រូវមាន ជា ចាំបាច់ សំរាប់ ប្រជាជាតិ និមួយៗ៕

---

[6] អន្ធជន គឺ ជា ជនថោកទាប។